ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

107
11.01.

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខៈ ១៣១៦ "ឃ" ក្រ១០
-ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦៣
ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ ២០៣៧
ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ ៣០៥៦
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង៣០នាទី ព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាព ៖

## ប្រធានក្រុមជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦៣ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការៈធ្លាប់ជាប់ពន្ធនាគាររយៈពេល០៣ឆ្នាំ ពីបទៈប៉ុនប៉ងលួច នៅឆ្នាំ២០១២ ជានីតិជន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ៦៣៥៣ "ង១" ជ.ឃ.ង ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ នៅមណ្ឌលអប់រំកែប្រែទី០១ (ម១) ព្រៃស។

ជាប់ចោទពីបទ ៖ លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម៉ូតូ) ប្រព្រឹត្តនៅចំណុចបន្ទប់ជួលភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ ,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនិច ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មានអាសយដ្ឋានបច្ចុប្បន្នផ្លូវលេខ៤៦៦ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

-លោក [redacted] ចាន់សុវណ្ណដា អគ្គលេខ២០៥៩T ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ០៣ និង៤០ នាទី ជនរងគ្រោះឈ្មោះ [redacted] ស្រីនិច ភេទស្រី អាយុ២៤ឆ្នាំ បានចតទុកម៉ូតូរបស់ខ្លួនម៉ាក ស៊ុយហ្សាគីនិច ពណ៌ទឹកប្រាក់ ពាក់ផ្លាកលេខស្វាយរៀង 1N-8187 ចតទុកនៅក្រៅរបងផ្ទះជួល ស្ថិតក្នុងភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ដោយបានចាក់សោរកត្រឹមត្រូវ និងឡើងទៅសម្រាកក្នុងបន្ទប់ជាន់ទី១ ។ វេលាម៉ោង ០៣ ទាបភ្លឺ ក៏មានជនសង្ស័យម្នាក់ឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ធ្វើសកម្មភាពកាច់បំបាក់សោរកម៉ូតូបញ្ចោះជិះរត់គេចខ្លួនបាត់ ហើយយកទៅដូរគ្រឿងបន្លាស់ម៉ូតូម្តង ហើយបន្តយកទៅបញ្ចាំនៅម្តុំផ្សារឃ្លាំងរំសេវក៏ត្រូវសមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ ឃាត់ខ្លួនតាមបណ្តឹងរបស់ជនរងគ្រោះ រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតែម្តង ។

-**បានឃើញ** របាយការណ៍សំយោគលេខ: ០៩៥/២០ រ.ប.ក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ អធិការដ្ឋាននគរបាលខណ្ឌមានជ័យ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ២១៧៧ អ.យ.ឃ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ២៦០៣ អ.យ.ឃ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចរក្សាជនត្រូវចោទក្នុងឃុំបណ្តោះអាសន្នឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ លេខ: ៦៣៥៣ “ង១” ដ.ឃ.ដ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣៣៧៨ “ង១” ដ.ដ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ឯកសារភស្តុតាងនានានៅក្នុងសំណុំរឿង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ បានឆ្លើយសារភាពថា៖ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ខ្លួនបានលួចម៉ូតូរបស់គេដោយប្រើមធ្យោបាយយកទុលឡាវីសឆ្កើសយកជិះចេញទៅ ។ ក្រោយមកសមត្ថកិច្ចក៏បានឃាត់រូបខ្លួន ។ ខ្លួនសំណូមពរសុំឲ្យតុលាការមេត្តាបន្ធូបន្ថយទោសដល់រូបខ្លួនផងខ្លួនដឹងខុសហើយ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនិច អវត្តមាននាពេលសវនាការ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច , ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរមានលក្ខណៈប្រហាក់ប្រហែលគ្នាថា ៖កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៣ ទាបភ្លឺ នៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ខ្លួនបានធ្វើសកម្មភាពលួចកាច់កម្ម៉ូតូ ០១គ្រឿង ម៉ាកSUZUKI NEX ពណ៌ទឹកប្រាក់ មិនចាំផ្លាកលេខ ដែលជាម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន ដោយធ្វើសកម្មភាពតែម្នាក់ឯងទេ ។ ពេលលួចម៉ូតូបានសម្រេចហើយ ខ្លួនក៏បានជិះម៉ូតូនោះទៅម្តុំផ្សារឃ្លាំងរំសេវដើម្បីដោះកុងទ័រម៉ូតូលក់ឲ្យក្មេងៗនៅម្តុំនោះ បានប្រាក់ចំនួន ២៥ ដុល្លារអាមេរិក បន្ទាប់មកខ្លួនបានជិះម៉ូតូនោះទៅផ្ទះវិញ ដោយជិះទៅដល់ចំណុចក្បែរកន្លែងចាក់សំរាម ផ្លូវលេខ៣៧១ វេលាម៉ោង១២ ថ្ងៃត្រង់ ក៏មានកំលាំងកងរាជអាវុធហត្ថចាប់ឃាត់ខ្លួន រួមទាំងម៉ូតូដែលខ្លួនបានលួចនោះតែម្តង ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនិច បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចថា: នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៧ និង ៣០នាទី នៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ខ្លួនបានចតម៉ូតូនៅក្រៅរបងមុខផ្ទះ ដែលមានម៉ូតូម៉ាក SUZUKI NEX ពណ៌ទឹកប្រាក់ ស្លាក់លេខស្វាយរៀង 1N-8187 លេខម៉ាស៊ីន AE 52343863 លេខតួ CE44F343435 ផលិតឆ្នាំ២០១៩ ។ ខ្លួនបានចាក់សោរម៉ូតូ រួចក៏បានឡើងទៅលើបន្ទប់ជួលជាន់ទី១ ។ លុះដល់ម៉ោងប្រហែល ០៨ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ ខ្លួនបានភ្ញាក់ពីគេងរួចបានដើរចុះមកក្រោមរកមើលម៉ូតូតែមិនឃើញ ។ ក្រោយមកខ្លួនបានសុំមើលកាំមេរ៉ាសុវត្ថិភាពរបស់ម្ចាស់ផ្ទះជួល ក៏បានឃើញសកម្មភាពចោរលួចកាច់កម្ម៉ូតូរបស់ខ្លួន ។ រហូតមកដល់ម៉ោងប្រហែល ១៤ និង១០នាទីថ្ងៃដែល ខ្លួនបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍បឹងត្របែក ។ លុះដល់ម៉ោងប្រហែល ១៥ និង២០នាទី ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ សមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌមានជ័យ បានខលទាក់ទងខ្លួន ថាបានរកឃើញម៉ូតូម៉ាក SUZUKI NEX ពណ៌ទឹកប្រាក់ ស្លាក់លេខស្វាយរៀង 1N-8187 ដែលពេលនោះខ្លួនបានទៅដល់កន្លែងសមត្ថកិច្ច ក៏បានឃើញម៉ូតូរបស់ខ្លួនដែលបានបាត់ពិតប្រាកដមែន ។

## សេចក្តីសន្និដ្ឋានម្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ បានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម៉ូតូ) ដូចការចោទប្រកាន់មែន ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ២៦០៣ អ.យ.ឍ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល និងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ជាធរមាន ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោក [redacted] ចាន់សុវណ្ណដា អត្តលេខ២០៤៩T ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ បានធ្វើសេចក្តីសន្និដ្ឋាន: ក្រោយពីផ្លែងកាត់ការដេញដោលនាពេលសវនាការរួចមក ឃើញកូនក្តី

ខ្លួនបានសារភាព និងទទួលកំហុស ថាពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូចនេះខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួន ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ បាននិយាយសំដីចុងក្រោយបង្អស់ថា សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៣ និង៤០ នាទី ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ពិតជាមានករណី៖ **លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម្ម៉ូតូ)** កើតឡើងដែលបង្កឡើងដោយឈ្មោះ [redacted] **បញ្ញាវុធ** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ពិតប្រាកដមែន។

២-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៣៣៧៨ "២១ ដ.ង ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ **ស្វន បញ្ញាវុធ** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម្ម៉ូតូ)** ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-ឆ្លងតាមការឆ្លើយសារភាពរបស់ជនជាប់ចោទ និងឆ្លងតាមការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា មានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] **បញ្ញាវុធ** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម្ម៉ូតូ) ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើទៅតាមនីតិវិធីច្បាប់ ។

៤-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មានកាយសម្បទាគ្រប់គ្រាន់ ពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានបញ្ហាវិបល្លាសស្មារតីក្នុងពេលកំពុងប្រព្រឹត្តបទល្មើសនោះទេ ម្យ៉ាងវិញទៀតជនជាប់ចោទមានលទ្ធភាពអាចពិចារណា និងដឹងយ៉ាងច្បាស់ថាអំពើប្រព្រឹត្តរបស់ខ្លួន គឺខុសទៅនឹងច្បាប់ព្រហ្មទណ្ឌ ដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ដូច្នេះជនជាប់ចោទគ្រប់លក្ខខណ្ឌ ដែលអាចទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន តាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

៥-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការទៅលើជនជាប់ចោទខាងលើ គឺមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អាចឱ្យតុលាការលើកយកមកពិចារណាបាន ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម៉ូតូ) ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ ,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ (បួន) ឆ្នាំ ។

ពីបទ: លួចមានស្ថានទម្ងន់ទោស (កាច់បំបាក់សោរកម៉ូតូ) ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ភូមិ៨ សង្កាត់បឹងត្របែក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បញ្ញាវុធ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហាស់ ស្រីនិច ។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ច័ន្ទ ០៨កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ , ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមជំនុំជម្រះ

[redacted]

[redacted]